# លិខិតពីតេហ្សេ - បងប្រុស អាលីយ៉ូស ( Br.ALIOS )

## សេចក្តីក្លាហានដើម្បីបង្ហាញមេត្តាករុណា

ពេញមួយឆ្នាំ 2015 កន្លងមក យើងនៅតេហ្សេ បានស្វែងរកវិធីជាច្រើន ដើម្បីប្តេជ្ញាចិត្ត រួមសាមគ្គីតាមបែបថ្មី ។ ក្នុងពេលបច្ចុប្បន្នកាល ការរួមសាមគ្គីបែបថ្មីនេះ ពិតជាភារកិច្ចដ៏បន្ទាន់ និងសំខាន់ជាទីបំផុត។ ជាក់ស្តែងនៅលើភពផែនដីនេះ គឺមានទម្រង់ថ្មីផ្សេងៗគ្នា ជាច្រើនដែលជាកង្វល់ ដូចជា៖ **ជនអន្តោប្រវេសន៍ ជាច្រើនអនេកមានបញ្ហាប្រែប្រួលបរិស្ថានធម្មជាតិ បញ្ហាចលាចលកើតមានក្នុងសង្គមជាដើម** ដែលទាំងនោះគឺជាការប្រឈមចំពោះមនុស្សជាតិទាំងអស់ មិនថាអ្នកកាន់សាសនា ឬអ្នកដែលមិនមានសាសនានោះទេ ។

អំពើហិង្សាប្រដាប់អាវុធដែលកើតចេញពីមនោគមវិជ្ជា គឺកំពុងបង្ហាញឲ្យឃើញច្បាស់ នូវវិនាសកម្មផ្សេងៗ និងការកាប់សម្លាប់មនុស្សយ៉ាងឃោរឃៅ ។ ជាក់ស្តែងណាស់ ខណៈពេលដែលកំពុងនឹកឃើញនូវទិដ្ឋភាពទាំងនោះ គឺយើងត្រូវតែកាន់ទិសឲ្យច្បាស់ ដោយបន្ត **«បូជនីយចរទៅរកសេចក្តីទុកចិត្ត»** ដែលជាវិធីមួយដ៏ប្រសើរដើម្បី ទប់ទល់នឹងការភ័យខ្លាច ដែលបានបង្ករឡើងដោយអសន្តិសុខសង្គម ។ លើសពីនេះទៅទៀត វាបន្ទាន់ និង មានសារៈសំខាន់លើសអ្វីៗ ទាំងអស់ គឺយើងត្រូវគាំទ្រ និងលើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីស្វែង រកឲ្យ ឃើញនូវជីវិត ប្រកបដោយសាមគ្គីភាព ក្នុងសកលភាវូបនីយកម្មនេះ ។

*ទោះបីភ្លៀងបង្អុរ ចុះមក ហើយមានទឹកជន់ មានខ្យល់បក់បោកប៉ះនឹងផ្ទះនោះយ៉ាងណាក៏ដោយ ក៏ផ្ទះនោះមិនរលំដែរ ព្រោះមានគ្រឹះនៅលើផ្ទាំងថ្ម (ម៉ាថាយ 7: 24-25) ។*

ព្រះបន្ទូលរបស់ព្រះគ្រីស្ត គឺជាមូលដ្ឋានគ្រិះសម្រាប់យើង ដែលយើងចង់កសាងជីវិតលើព្រះបន្ទូលរបស់ព្រះអង្គ ។ ដូច្នេះត្រូវយកសេចក្តីខ្លះៗធ្វើជាថ្មចាកគ្រឹះ ដែលមនុស្សទាំងអស់អាចយកបាន គឺ ៖ ***អំណរសប្បាយរស់នៅតាមបែបមនុស្សធម្មតា និងមេត្តាករុណា*** ។ បងប្រុស Roger បានដាក់ព្រះបន្ទូលទាំងអស់នេះជាបេះដូង នៃជីវិតរបស់សហគមន៍ តេហ្សេ, ហើយព្រះបន្ទូលទាំងអស់នោះបានជំរុញឲ្យគាត់ទៅមុខរហូតទោះបីជា មានការលំបាកជាច្រើនយ៉ាងណាក៏ដោយ ។ ហើយបងប្រុសបានធ្វើឲ្យជីវិតរបស់គាត់ដូចទៅនឹងសេចក្តីទាំងអស់នោះក្នុងការរស់នៅជារៀងរាល់ថ្ងៃ ។

សូមយកពាក្យទាំងបីខាងលើនេះណែនាំយើងក្នុងដំណើរជីវិតសម្រាប់ ៣ឆ្នាំខាងមុខទៀត ។ ហេតុនេះក្នុងឆ្នាំ ២០១៦នេះ គួរតែចាប់ផ្តើមជាមួយពាក្យ**មេត្តាករុណា** ដោយដើរស្របជាមួយនឹង**ឆ្នាំនៃការ សម្តែងមេត្តាករុណា** ដែលសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានប្រកាសកន្លងមកហើយ ។

លើសពីនេះទៅទៀត ព្រះបន្ទូលដំណឹងល្អរបស់ព្រះយេស៊ូ បានត្រាស់ហៅយើងឲ្យខិតខំធ្វើជាសាក្សីនៃព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតា ។ ដូច្នេះហើយ ខ្ញុំបានដាក់សំណើប្រាំសម្រាប់ឲ្យយើងភ្ញាក់ និងដាស់ស្មារតីយើងឲ្យមានចិត្តក្លាហានដើម្បីសម្តែងមេត្តាករុណា ។

***Brother Alois បងប្រុស អាលីយ៉ូស***

## សំណើទីមួយ

## សូមផ្ញើជីវិតរបស់យើងទាំងស្រុងលើព្រះបិតាដែលមានព្រះហឫទ័យមេត្តាករុណា

*ព្រះអង្គជាព្រះដែលតែងតែអត់ទោស, ព្រះអង្គប្រកបដោយព្រះហឫទ័យ អាណិតអាសូរ និងប្រណីសន្ដោស, ព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ និងពោរពេញដោយព្រះហឫទ័យមេត្តាករុណា និង ពោរពេញដោយសេចក្ដីស្រឡាញ់ (នេហេមី ៩:១៧)*

ចូរមានចិត្តមេត្តាករុណា ដូចព្រះបិតារបស់អ្នករាល់គ្នាដែលមានព្រះហឫទ័យមេត្តាករុណា ***(លូកា ៦:៣៦)***

តាមអត្ថបទព្រះគម្ពីរ គឺព្រះបិតាជាប្រភពនៃមេត្តាករុណា ព្រះអង្គប្រកបដោយព្រះហឫទ័យអាណិតអាសូរ និងប្រណីសន្ដោស ។ ព្រះយេស៊ូមានព្រះបន្ទូលជាប្រាស្នាអំពីឪពុក និងកូនប្រុសពីរនាក់ (លូកា ១៥) គឺព្រះយេស៊ូបានបង្ហាញឲ្យយើងឃើញច្បាស់ថា ព្រះជាម្ចាស់ជាព្រះបិតា ព្រះអង្គស្រឡាញ់យើងមិនមែនទាល់តែយើងធ្វើអ្វីដែលល្អៗ នោះទេ ប៉ុន្ដែព្រះអង្គបានស្រឡាញ់យើងដោយគ្មានល័ក្ខខ័ណ្ឌ ។ ឪពុកស្រឡាញ់កូនប្រុសច្បងដែលបានបម្រើគាត់ពេញមួយជីវិត ហើយឪពុកក៏ទន្ទឹងរង់ចាំកូនប្រុសដែល នៅឆ្ងាយពីគាត់ក្នុងសេចក្ដីស្រឡាញ់ និងបើកដៃទាំងពីររង់ចាំដើម្បីស្វាគមន៍កូន ឱបកូនដែលបានចាកចេញទៅហើយ ។

ព្រះជាម្ចាស់បានប្រតិដ្ឋានយើងមកឲ្យមានរូបរាងដូចព្រះអង្គផ្ទាល់ ។ ហេតុនេះ «យើងត្រូវមានលក្ខណៈដ៏ប្រសើរដូចព្រះអង្គ ដោយទទួលព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ។ យើងបានទទួលចិត្តប្រណីសន្ដោស យើងទទួលបានចិត្តសប្បុរស ដើម្បីបំពាក់ព្រះគ្រីស្ដដូចសម្លៀកបំពាក់ដែលយើងពាក់ក្នុងជីវិតយើង» *(Basil of Caesarea, fourth century).*

សេចក្ដីស្រឡាញ់របស់ព្រះបិតា គឺមិនមែនមានតែមួយភ្លែតប៉ុណ្ណោះទេ ប៉ុន្ដែព្រះអង្គស្រឡាញ់យើងគ្រប់ពេលវេលា។ ដោយយើងជាគ្រីស្ដបរិស័ទ និងដោយចិត្តប្រណីសន្ដោសរបស់យើងផ្ទាល់ គឺយើងដូចជាពន្លឺដែលបង្ហាញនូវសេចក្ដីស្រឡាញ់នេះ ។ ហេតុនេះក្នុងឋានៈយើងជាគ្រីស្ដបរិស័ទ យើងអាចចែករំលែកសេចក្ដីស្រឡាញ់នេះដល់អស់អ្នកដែលមានជំនឿផ្សេងៗ ឲ្យយកចិត្តទុកដាក់ ចាប់អារម្មណ៍ដើម្បីធ្វើឲ្យធម៌មេត្តាករុណា និងប្រណីសន្ដោស ជាមូលដ្ឋានគ្រឹះនៃជីវិតរបស់យើងម្នាក់ៗ ។

++យើងត្រូវបើកចិត្តទទួលស្វាគមន៍សេចក្ដីស្រឡាញ់របស់ព្រះបិតា ។ ពីព្រោះព្រះអង្គមិនដែលលែងស្រឡាញ់យើងនោះទេ ។ ហើយសេចក្ដីស្រឡាញ់ដែលពោរពេញដោយព្រះហឫទ័យ សប្បុរសរបស់ព្រះជាម្ចាស់គឺតែងតែថែរក្សាការពារយើងជានិច្ច ទោះបីជាយើងដួលដោយសារអំពើបាប ដែលយើងបានប្រព្រឹត្តខុសយ៉ាងណាក៏ដោយ ។ ប្រសិនបើយើងបានឃ្លាតឆ្ងាយពីព្រះអង្គ សូមកុំភ័យខ្លាច នឹងវិលត្រឡប់ មករកព្រះអង្គវិញ ហើយសុំទុកចិត្តលើព្រះអង្គចុះ ពីព្រោះព្រះបិតាតែងតែយាងមកជួបយើងជានិច្ច ។

++យើងមិនគួរចាត់ទុកការអធិដ្ឋានជាការស្វែងរកទាំងលំបាកនោះទេ, ប៉ុន្ដែត្រូវទទួលការអធិដ្ឋានទុកជាពេលវេលាដែលឈប់សម្រាក ហើយដកដង្ហើមមួយៗ ។នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធគង់ សណ្ឋិតលើ

យើង ហើយណែនាំយើងឲ្យពោរពេញដោយសេចក្ដីស្រឡាញ់របស់បិតា ពេលនោះយើងអាចបន្តការរស់នៅរបស់ យើងទាំងបង្ហាញចិត្តមេត្តាករុណាដល់គេបាន ។

## សំណើទី ២

## សូមលើកលែងទោសឲ្យគ្នាទៅវិញទៅមកម្ដងហើយម្ដងទៀត

*បងប្អូនត្រូវតែកាន់ចិត្តអាណិតមេត្តា ចិត្តល្អ សប្បុរស ចេះបន្ទាបខ្លួន មានចិត្តស្លូតបូត និងចិត្តខន្តី អត់ធ្មត់។ ត្រូវចេះទ្រាំទ្រ គ្នាទៅវិញទៅមក ហើយប្រសិនបើបងប្អូនណាម្នាក់មានរឿងអ្វីមួយនឹងម្នាក់ទៀត ត្រូវតែអត់ទោសឲ្យគ្នាទៅវិញទៅមក។ ព្រះអម្ចាស់បានអត់ទោសអោយបងប្អូនយ៉ាងណា ចូរអត់ទោសឲ្យគ្នាទៅវិញទៅមកយ៉ាងនោះដែរ។ (កូឡូស ៣:១២-១៣)*

*ពេលនោះ លោកសិលាចូលមកជិតព្រះយេស៊ូ ហើយទូលថា៖«បពិត្រព្រះអម្ចាស់ បើបងប្អូនចេះតែប្រព្រឹត្តអំពើបាបមកលើទូលបង្គំ តើទូលបង្គំត្រូវអត់ទោសអោយគេប៉ុន្មានដង? រហូតដល់ប្រាំពីរដងឬ?»។ ព្រះយេស៊ូមាន ព្រះបន្ទូលទៅគាត់ថា៖«ខ្ញុំសុំប្រាប់អ្នកថា អ្នកត្រូវអត់ទោសអោយគេ មិនត្រឹមតែប្រាំពីរដងប៉ុណ្ណោះទេ គឺត្រូវអត់ទោសអោយគេចិតសិបដងប្រាំពីរដង»។ (ម៉ាថាយ ១៨:២១-២២)*

ព្រះជាម្ចាស់មិនដែលឈប់លើកលែងទោសឲ្យយើងឡើយ ។ គ្រប់ពេលវេលាក្នុងដំណើរជីវិត របស់ព្រះគ្រីស្ដ សូម្បីតែនៅពេលព្រះយេស៊ូនៅលើឈើឆ្កាងក្ដី ក៏ព្រះអង្គបានលើកលែងទោសឲ្យគេដែរ ។ គឺព្រះអង្គមិនព្រមដាក់ទោសនរណាម្នាក់សោះឡើយ ។

យើងត្រូវដឹងថា ពេលយើងត្រូវបានគេលើកលែងទោសឲ្យ ហើយយើងបានលើកលែងទោសឲ្យគេវិញ នោះគឺជាពេលវេលាដែលមានអំណរសប្បាយ និងមានសេរីភាពពេញលេញបំផុត ។ ការលើកលែងទោសដូច្នេះគឺជាប្រភពនៃសេចក្ដីសុខសាន្តក្នុងចិត្ត ដែលព្រះយេស៊ូគ្រីស្ដសព្វព្រះហឫទ័យលើកលែងទោសឲ្យយើង ។

ព្រះសហគមន៍ គឺជាកន្លែងដែលប្រមូលផ្ដុំអស់អ្នកដែលស្រឡាញ់ព្រះគ្រីស្ដ។ ព្រះអង្គសូមឲ្យ ព្រះសហគមន៍បណ្ដោយខ្លួនឲ្យព្រះហឫទ័យមេត្តាករុណាកែប្រែខ្លួន ។ ជាការពិតណាស់ «នៅពេលដែលព្រះ សហគមន៍ស្ដាប់ឮសូរសម្រែករបស់មនុស្ស, ពេលព្រះសហគមន៍សង្គ្រោះព្យាបាលគេ និងធ្វើការផ្សះផ្សាសម្រុះសម្រួល, នៅពេលនោះហើយ ដែលជាពេលបញ្ចេញបន្លឺយ៉ាងខ្លាំងបំផុត ក្នុងរូបភាពនៃសេចក្ដីស្រឡាញ់ និងការរួបរួមគ្នាជាធ្លុងតែមួយ, ជាពេលដែលបង្ហាញចិត្តមេត្តាករុណា, ជាពេលវេលាដែលបង្ហាញនូវការលើកទឹកចិត្ត, ទាំងអស់នេះ គឺបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ ព្រះយេស៊ូគ្រីស្ដមានព្រះជន្ម រស់ឡើងវិញដ៏រុងរឿងមែន»។ ដោយសារព្រះយេស៊ូគ្រីស្ដមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង ធ្វើឲ្យយើងមិនឃ្លាតឆ្ងាយពីគ្នា, ធ្វើឲ្យយើងមិនឈ្លោះទាស់ទែងគ្នា, ធ្វើឲ្យយើងរួចផុតពីការ និយាយមិនពិរោះដាក់គ្នា ចេះគោរពគ្នា, ដែលសកម្មភាពទាំងអស់នេះ អាចណែនាំឲ្យយើង មានភាពទន់ភ្លន់សុភាព រាបសា មានជំនឿចិត្ត ហើយជាពន្លឺបំភ្លឺដួងចិត្តយើងក្នុងការរស់នៅជាមនុស្ស ។ *(Brother Roger)*

ព្រះហឫទ័យនៃការលើកលែងទោសរបស់ព្រះជាម្ចាស់មិនអាចប្រើជាការបញ្ជាក់នូវអំពើអាក្រក់ ឬភាពអយុត្តិ-ធម៌បានទេ ។ ផ្ទុយទៅវិញ, គឺធ្វើឲ្យយើង មានសេរីភាពទទួលស្គាល់នូវកំហុសរបស់យើងផ្ទាល់ មិនគ្រាន់

តែកំហុស និងភាពអយុត្តិធម៌មិននៅជុំវិញយើងប៉ុណ្ណោះទេ គឺនៅក្នុងពិភពលោកទាំងមូល ប៉ុន្តែវាអាស្រ័យលើយើងធ្វើអ្វីដែលត្រឹមត្រូវ ហើយអាចធ្វើអ្វីៗទាំងអស់នោះឲ្យមានភាពត្រឹមត្រូវ ។

++សូមយើងព្យាយាមលើកលែងទោសឲ្យគ្នា - ទោះបីជាចិត្តសិបប្រាំពីរដងប្រាំពីរដង ។ ប្រសិនបើស្នាមរបួសគឺកាន់តែធំទៅៗ សូមយើងព្យាយាម ព្យាបាលវាបន្តិចម្តងៗតាមដំណាក់កាល ។ មុនពេលវាកើតបញ្ហាធំគឺសូមឲ្យបំណងនៃការលើក លែងទោស អាចធ្វើឲ្យពេលវេលាដែលបានឈឺចាប់បាត់ស្រមោលទៅ ។

++យើងអាចបង្ហាញថា ព្រះសហគមន៍ គឺជាកន្លែងមួយដែលបង្ហាញធម៌មេត្តាករុណា ដោយចាប់ផ្តើមបើកទ្វាចំហ, គ្មានភាពរើសអើង ដល់អស់អ្នកដែលនៅជុំវិញយើង បង្ហាញនូវការស្វាគមន៍ប្រកបដោយភាពពក់ទាក់ដោយមិនថ្កោលទោស វិនិច្ឆ័យកាត់ក្តីលើអ្នកដទៃជាដាច់ខាត បង្ហាញពីការការពារដោយមិនជិះជាន់សង្កត់សង្កិនអ្នកដទៃ បង្ហាញពីការអប់រំចិត្តរបស់យើងដោយយកចិត្តទុកដាក់ផ្តល់ភាពកក់ក្តៅ និងចិត្តសប្បុរសរបស់យើង ។

## សំណើរទី ៣

## សូមចូលទៅជិតអស់អ្នកដែលមានស្ថានភាពទុក្ខព្រួយ, មានអារម្មណ៍ឯកោ ឬគ្មានអ្នកចាប់អារម្មណ៍

*ប្រសិនបើអ្នកសុខចិត្តបេះអាហារពីមាត់ខ្លួន យកទៅអោយអ្នកដែលស្រេកឃ្លាន ប្រសិនបើអ្នកយកម្ហូបអាហារទៅចម្អែតមនុស្សទុគ៌ត នោះពន្លឺរបស់អ្នកនឹងចែងចាំងក្នុងទីងងឹត ហើយភាពងងឹត របស់អ្នកនឹងប្រែទៅជាភ្លឺដូចពន្លឺថ្ងៃត្រង់ដែរ។ (អេសាយ ៥៨:១០)*

*ប្រសិនបើនរណាម្នាក់ មានសម្បត្តិលោកីយ៍ ហើយឃើញបងប្អូនរបស់ខ្លួនខ្វះខាត តែបែរជាមិនអាណិតអាសូរគេទេនោះ ធ្វើដូចម្តេចនឹងអោយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ស្ថិតនៅក្នុងខ្លួនអ្នកនោះកើត ! (១យ៉ូហាន ៣:១៧)*

នៅក្នុងរូបភាពនៃធម៌មេត្តាករុណា ព្រះគ្រីស្តកំពុងសម្លឹងមើលយើងជាមួយសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ ហើយព្រះអង្គមានព្រះបន្ទូលមកកាន់យើងអំពីសាសន៍សាម៉ារីដ៏សប្បុរស (លូកា ១០), មានបុរសម្នាក់រងរបួសស្ទើរតែស្លាប់នៅតាមផ្លូវ ហើយមានបូជាចារ្យម្នាក់ និង ម្នាក់ពីក្រុមលេវីបានធ្វើដំណើរកាត់នោះ ឃើញហើយក៏ដើរជៀសបន្តដំណើរទៅមុខទៀត ប៉ុន្តែមានជនបរទេសម្នាក់ដែលជាជនជាតិសាម៉ារី បានចូលទៅជិតអ្នករបួសនោះ រួចគាត់លើកអ្នករបួសដាក់លើជំនិះរបស់គាត់ នាំទៅផ្ទះសំណាក់ ហើយថែទាំអ្នករបួសនោះ។

ធម៌មេត្តាករុណាគឺត្រូវបើកដួងចិត្តរបស់យើងទៅក្នុងទុក្ខលំបាករបស់អ្នកដទៃ, បើកចិត្តរបស់យើងដើម្បីយល់ពីទុកព្រួយរបស់គេដែលកប់ទុកក្នុងចិត្ត, បើកចិត្តរបស់យើងដើម្បីយល់អំពីអ្នកក្រីក្រខ្វះខាត និងអ្នកដែលទទួលរងនូវការឈឺចាប់ផ្សេងៗ, បើកចិត្តរបស់យើងដើម្បីយល់អំពីក្មេងដែលឆ្លងកាត់ពេលវេលាដ៏លំបាក, បើកចិត្តរបស់យើងដើម្បីយល់អំពីទុក្ខលំបាករបស់ក្រុមគ្រួសារមួយ, បើកចិត្តរបស់យើងដើម្បីជួយអ្នកដែលគ្មានផ្ទះស្នាក់នៅ, បើកចិត្តរបស់យើងដើម្បីជួយលើកទឹកចិត្តដល់មនុស្សពេញវ័យដែលមើលឃើញជីវិតខ្លួនឯងថាគ្មានតម្លៃ និងគ្មានអត្ថន័យ, បើកចិត្តរបស់យើងដើម្បីផ្តល់ភាពកក់ក្តៅដល់បុរស ឬស្ត្រីដែលមានភាពកម្សត់ទុរគត,

បើកចិត្តរបស់យើងដើម្បីស្វាគមន៍ជនបរទេស ឬអ្នកចំណាកស្រុក, បើកចិត្តរបស់យើងដើម្បីជួយអប់រំណែនាំដល់អស់អ្នកដែលគ្មានឱកាសទទួលការអប់រំ, បើកចិត្តរបស់យើងដើម្បីបង្រៀន និងចែករំលែកដល់អ្នកដែលចង់ដឹងអំពីវប្បធម៌ប្រពៃណី ។

ព្រះគ្រីស្តស្ថិតក្នុងចំណោមអ្នកក្រីក្រទាំងអស់នោះ ព្រះអង្គដាក់ព្រះហឫទ័យ លើចិត្តមេត្តាករុណារបស់យើងម្នាក់ៗ ដូចព្រះអង្គបានមានព្រះបន្ទូលមកកាន់យើងថា «កាលខ្ញុំស្រេកឃ្លាន អ្នករាល់គ្នាបានយក អាហារមកឲ្យខ្ញុំបរិភោគ» (ម៉ាថាយ ២៥) ។ តាមលោក Maximus បានបង្ហាញថា «ដោយព្រះហឫទ័យមេត្តាករុណាប្រណីសន្ដោស, ព្រះគ្រីស្ដបានទទួលរងទុក្ខលំបាកគ្រប់បែបយ៉ាងសំរាប់មនុស្សលោក ហើយការចែករំលែកទុក្ខ លបាករបស់ព្រះអង្គសំរាប់មនុស្សម្នាក់ៗ គឺជាអាថិកំបាំង រហូតដល់ទីបញ្ចប់នៃពិភពលោក» *(Maximus the Confessor, seventh century).*

ព្រះគ្រីស្ដតែងតែមានព្រះហឫទ័យយកចិត្តទុកដាក់ថែរក្សាយើង នៅពេលដែលយើងត្រូវបានរងការឈឺចាប់ដោយសារការវិនិច្ឆ័យផ្សេងៗ ។ ព្រះអង្គទតមើលមកយើងដោយសេចក្ដីស្រឡាញ់ ដែលសេចក្ដីស្រឡាញ់នេះស្តែងចេញតាមរយៈ មនុស្សម្នាក់ដែលមកជិតយើង លើកទឹកចិត្តយើង ពេលខ្លះតាមរយៈមនុស្សម្នាក់ដែលយើងនឹកស្មានមិនដល់ ដូចជាប្រស្នាអំពីអ្នកសាសន៍សាម៉ារី អីចឹងដែរ ។

++ សូមចូលទៅជិតអស់អ្នកដែលមានស្ថានភាពទុក្ខព្រួយ, អស់អ្នកដែលមានអារម្មណ៍ឯកោ ឬគ្មានអ្នកចាប់អារម្មណ៍ ដើម្បីយល់ពីទុក្ខលំបាករបស់គេ សូមយល់នូវទុក្ខព្រួយរបស់អ្នកដែលនៅជុំវិញយើង និងអស់អ្នកដែលយើងមើលឃើញតាមដងផ្លូវយើងឆ្លងកាត់ ។ ពីព្រោះធម៌មេត្តាករុណា គឺមិនមែនគ្រាន់តែជាមនោសញ្ចេតនាប៉ុណ្ណោះទេ ប៉ុន្តែជាការទាមទាឲ្យធ្វើ ហើយវាគ្មានដែនកំណត់នោះទេ ។ យើងត្រូវចាំថា ច្បាប់មួយចែងមក គឺមានដែនកំណត់យ៉ាងច្បាស់លាស់នូវទំហំនៃកាតព្វកិច្ច ចំណែកធម៌មេត្តាករុណាវិញមិនដែលនិយាយថា «នោះគឺគ្រប់គ្រាន់ហើយ ! ខ្ញុំបានធ្វើនូវកាតព្វកិច្ចរបស់ខ្ញុំរួចរាល់អស់ហើយ » ។

## សំណើរទី ៤

## សូមព្យាយាមយកចិត្តទុកដាក់បង្ហាញមេត្តាករុណាដល់គ្រប់ផ្នែកទាំងអស់នៅក្នុងសង្គម

*«យើងជាព្រះអម្ចាស់ ដែលសម្តែងសេចក្ដីសប្បុរស សេចក្ដីសុចរិត និងយុត្តិធម៌នៅលើផែនដី» (យេរេមី ៩:២៣[២៤])*

ព្រះអម្ចាស់សព្វព្រះ ហឫទ័យអោយអ្នកធ្វើ គឺអ្នកត្រូវប្រតិបត្តិតាមយុត្តិធម៌ ស្រឡាញ់ភាពស្មោះត្រង់ ហើយយកចិត្តទុកដាក់ដើរតាមមាគ៌ានៃព្រះរបស់អ្នក ។ *(មីកា៦:៨)*

នៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់, មនុស្សយើងជាអ្នកដែលធ្វើឲ្យក្រុមគ្រួសារមួយកើតឡើងបាន ។ ហេតុដូច្នេះហើយធម៌មេត្តាករុណា គឺអាចពង្រីកវិសាលភាពយ៉ាងធំទូលាយនៅក្នុងសង្គម ។

សម្រាប់ពិភពលោកមួយនេះ ការរួបរួមសាមគ្គីអាចក្លាយជាការពិតបាន គឺវាមិនអាចខ្វះបានឡើយ នូវការពង្រឹងស្ថាប័នអន្តរជាតិដែលបានកំណត់នូវច្បាប់នៃការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ដើម្បីធានាបានថាមានភាពយុត្តិធម៌កាន់តែខ្លាំងនៅក្នុងសង្គម ហើយរក្សាបាននូវសុខសន្តិភាព ។

បំណុលរបស់បណ្តាប្រទេសក្រីក្រ គឺតែងតែបង្កឡើងដោយបណ្តាប្រទេសដែលមានអំណាច ហើយធ្វើអាជីវកម្មកេងប្រវ័ញ្ចលើធនធាននៃបណ្តាប្រទេសក្រីក្រ ។ បើទោះបីជាយើងមិនអាចធ្វើការផ្លាស់ប្តូរអ្វីបានសម្រាប់ បញ្ហានេះ ប៉ុន្តែសូមយើងចងចាំថាការអនុគ្រោះបំណុលនេះ គឺជាមធ្យោបាយមួយដើម្បីស្តារឡើងវិញនូវភាព យុត្តិធម៌ក្នុងសង្គម ។ នៅក្នុងបរិបទខុសគ្នាពីសព្វថ្ងៃនេះ, ព្រះគម្ពីរបានរំលឹកយើងថា៖ «ពេលបងប្អូនណាម្នាក់ របស់អ្នកធ្លាក់ខ្លួនក្រ និងខ្វះខាត ទោះបីអ្នកនោះជាជនបរទេស ឬជាអ្នកស្នាក់នៅបណ្តោះអាសន្នក្តី អ្នកត្រូវតែជួយគេ ដើម្បីឲ្យគេអាចរស់នៅក្បែរអ្នកតទៅមុខទៀត។ (លេវីវិន័យ ២៥:៣៥)

នៅទូទាំងពិភពលោក, បុរសស្ត្រី និងកុមារត្រូវបានគេបង្ខំឱ្យចាកចេញពីស្រុកកំណើតរបស់ពួកគេ។ ស្ថានភាពរបស់ពួកគេបែបនេះ នៅក្នុងចិត្តរបស់ពួកគេ គឺរឹតតែមានកម្លាំងខ្លាំងជាងធម្មតាទៅទៀត ដើម្បីជម្នះរាល់ឧបសគ្គទាំងឡាយ ។ ហេតុនេះបណ្តាប្រទេសអ្នកមានត្រូវតែដឹងថា ពួកគេត្រូវតែទទួលចំណែកនៃការទទួលខុសត្រូវនៃរបួសរបស់ប្រវត្តិសាស្រ្តមួយនេះ ដោយសារតែបណ្តាប្រទេសអ្នកមានទាំងនោះហើយ ដែលបាននាំឲ្យមានការបម្លាស់ទីយ៉ាងច្រើន ជាពិសេសមកពីទ្វីបអាហ្វ្រិក និងមជ្ឈឹមបូព៌ា ។

++វាជាការសំខាន់ណាស់ដែលយើងដឹងថា បើទោះបីជាការហូរចូលនៃជនភៀសខ្លួន និងជនចំណាកស្រុកបង្កឱ្យមានបញ្ហាលំបាកយ៉ាងណា ប៉ុន្តែនេះអាចជាជាឱកាសវិជ្ជមានផងដែរ ។ អស់អ្នកដែលគោះទ្វារស្នើសុំសិទ្ធជ្រកកោននៅបណ្តាប្រទេសអ្នកមាន គឺជម្រុញឲ្យប្រទេស ទាំងនោះរស់នៅក្នុងសាមគ្គីភាពថ្មី រួមជាមួយអស់អ្នកភៀសខ្លួនទាំងនោះបាន។ តើបណ្តាប្រទេសអ្នកមានទាំងនោះមិនជួយជនភៀសខ្លួនឱ្យទទួលបាននូវភាពរឹងមាំឡើងវិញបានទេ? បញ្ហាប្រឈម ដែលកើតឡើងពីកំណើននៃជន ចំណាកស្រុក ជាកង្វល់ដែលត្រូវរួមគ្នាដោះស្រាយ, ជាការពិតណាស់បណ្តាប្រទេសនៃសហគមន៍អឺរ៉ុប គួរតែជាអ្នកដែលជួយពន្លត់នូវបញ្ហាដែលបានកើតឡើងនេះឲ្យទទួលបាននូវភាពស្ងប់ទៅវិញ ។

++យើងចាំបាច់ត្រូវការមើលលើពីភាពភ័យក្លាចរបស់អ្នកស្នាក់នៅប៉ុណ្តុះអាសន្ន ឬជនភៀសខ្លួនទាំងអស់នោះ និងភាពខុសគ្នានៃវប្បធម៌ ។ ព្រោះថាភាពភ័យក្លាយ គឺអាចយល់បាន ប៉ុន្តែអស់អ្នកដែលជួយស្វាគមន៍ជនភៀសខ្លួន ទាំងអស់នោះ គឺពេលខ្លះអស់កំលាំងតែម្តង ពីព្រោះ ភាពភ័យក្លាចនិងមិនកាត់បន្ថយបានទេ បើទោះបីជាយើងទៅលាក់ខ្លួនពួននៅកៀនជញ្ជាំងយ៉ាងណាក៏ដោយ ប៉ុន្តែគឺប្រសើជាងដោយយើងទៅជិតអ្នកដែលយើងមិនទាន់ស្គាល់ដើម្បីឲ្យគេដឹង និងផ្តល់ភាពកក់ក្តៅ ដោយជំនួសពីការមើលឃើញនូវការគំរាមគំហែងចំពោះអ្នកដែលស្នាក់នៅបណ្តុះអាសន្ន ឬជនភៀសខ្លួនទាំងនោះ សូមសំឡឹងមកមើលកំរិតស្តង់ដានៃការស់នៅរបស់យើង ឬវប្បធម៌របស់យើង, តើវាគឺមិនមែនជាការបន្ទាន់ឬយ៉ាងណា ដើម្បីស្វាគមន៍អ្នកទាំងនោះជាសមាជិកនៃក្រុមមួយ ឬធ្វើឲ្យគេមានលក្ខណៈជាគ្រួសារដូចមនុស្ស ឬធ្វើឲ្យពួកគេមានសេចក្តីថ្លៃថ្នូជាមនុស្ស?

## សំណើរទី ៥

## សូមបង្ហាញមេត្តាករុណាដល់គ្រប់អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមក

*ក្នុងរយៈពេលប្រាំមួយ ថ្ងៃ អ្នកអាចធ្វើការងាររបស់អ្នកបាន ប៉ុន្តែ នៅថ្ងៃទីប្រាំពីរ អ្នកត្រូវគោរពថ្ងៃសប្ប័ទ* ដើម្បីឲ្យគោ និងលារបស់អ្នកបានសម្រាក។ (សេរីភាព២៣:១២)*

*ក្នុងរយៈពេលប្រាំមួយឆ្នាំ អ្នកអាចសាបព្រោះ និងប្រមូលផលពីស្រែចម្ការរបស់អ្នកបាន។ ប៉ុន្តែ នៅឆ្នាំទីប្រាំពីរ ត្រូវទុកដីនៅទំនេរ ដើម្បីឲ្យជនក្រីក្រ ក្នុងចំណោមប្រជាជនរបស់អ្នក អាចរកអាហារពីដីទាំងនោះ ហើយសត្វព្រៃនឹងមកស៊ីអ្វីៗដែលនៅសេសសល់។ (សេរីភាព ២៣:១០)*

នៅក្នុងពេលវេលានេះយើងអាចនិយាយបានថា ព្រះគម្ពីរបានត្រាស់ហៅយើងដើម្បីបង្ហាញចិត្តស្រឡាញ់បរិស្ថាន, គោរព និងថែរក្សាធម្មជាតិ ប្រើប្រាស់ដីឲ្យមានផលប្រយោជន៍។ គ្រីស្តបរិស័ទម្នាក់នៅ មេសូប៉ូតាមា បានសរសេថា *"ចិត្តអាណិតមេត្តាមិនអាចគ្រាន់តែឈរមើលនូវភាពទុក្ខព្រួយ ឬ អំពើអាក្រក់ដែលកើតមានក្នុងចំណោមភពផែនដីដែលព្រះជាម្ចាស់បានបង្កើតមកនេះបានទេ"* (Isaac the Syrian, seventh century).

ភាគច្រើនជនរងគ្រោះដោយមហន្តរាយនៃអេកូឡូស៊ី គឺមានភាពក្រីក្រខ្លាំងណាស់ ។ ផលប៉ះពាល់នៃការបម្រែបម្រួលអាកាសធាតុ គឺបានបង្ខំឲ្យមនុស្សជាច្រើនចាកចេញពីស្រុកកំណើតរបស់ខ្លួនទៅរស់នៅកន្លែងផ្សេង។

ផែនដីគឺជាកម្មសិទ្ធទាំងស្រុងរបស់ព្រះជាម្ចាស់ ដែលយើងជាមនុស្សលោកទទួលបានជាអំណោយមួយយ៉ាងពិសេសសំរាប់រស់នៅ ។ យើងទាំងអស់គ្នាទទួលភារកិច្ចយ៉ាងសម្បើមនេះ ដើម្បីថែរក្សាភពផែនដីមួយនេះ ដោយមិនឲ្យខ្ជះខ្ជាយនូវធនធានទាំងឡាយក្នុងភពផែនដីនេះ ។ គឺផែនដីនេះមានកំរិតរបស់វាដែរ ហើយយើងជាមនុស្សមិនត្រូវមានតំរូវការខ្ពស់ហួសពីព្រំដែនកំណត់នេះទេ ។

ផែនដីទាំងមូល គឺជាផ្ទះរបស់យើងទាំងអស់គ្នា ហើយបច្ចុប្បន្ននេះផែនដីទាំងមូលកំពុងតែហឹនហោចហើយ។ គឺវាកំពុងតែគ្មានកន្លែងដើម្បីបរិស្ថានបញ្ចេញនូវភាពស្រស់ស្អាតរបស់វាឡើយ ការបាត់បង់នូវប្រភេទសត្វព្រៃ ឬការគំរាមកំហែងដល់ជីវចំរុះ ការកាប់បំផ្លាញព្រៃឈើយ៉ាងច្រើននៅតាមតំបន់ជាច្រើនក្នុងពិភពលោកនេះ ៕

++ហេតុនេះ តើយើងអាចបង្ហាញនូវភាពសាមគ្គីរបស់យើងយ៉ាងដូចម្តេចបានសំរាប់ផែនដីដែលព្រះជាម្ចាស់បានបង្កើតឡើងនេះ ? ដោយការធ្វើសេចក្តីសម្រេចចិត្ត ដែលប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់យើង ដោយផ្តល់ការយកចិត្តទុកដាក់ពិចារណាយ៉ាងស៊ីជំរៅអំពីសកម្មភាពរបស់យើងក្នុងការប្រើប្រាស់ ឬជាប្រជាពលរដ្ឋដែលធ្វើសេចក្តីសម្រេចចិត្តជ្រើសរើសនូវជីវិតយ៉ាងសមញ្ញ ។ ការរស់នៅដោយសាមញ្ញ គឺជាមធ្យោបាយដើម្បីទទួលបាននូវអំណរសប្បាយ ។ មានមនុស្សមួយចំនួនបានចាប់ផ្តើមគិតអំពីការតមអាហារសំរាប់ការផ្លាស់ប្តូអាកាសធាតុ និងសំរាប់ភាពយុត្តិធម៌ ដោយពួកគេបានយកថ្ងៃទីមួយនៃដើមខែដើម្បីធ្វើកិច្ចការនេះ ។ សូមយកពេល វេលាដើម្បីឈានមួយជំហាន បង្ហាញពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ សំរាប់អ្វីទាំងអស់ដែលជាផ្ទះរួម របស់យើង ពីព្រោះផែនដី, គឺមិនមែនជាអ្វីមួយដែលយើងអាចធ្វើស្រេចតែចិត្តបានទេ; តែវាគឺជាលក្ខខណ្ឌសម្រាប់ការរស់នៅលើផែនដីនេះក្នុងសុភមង្គល។